១០៥

# តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៨២
ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១
សាលដីកា
លេខ: ២៩៧
ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២
ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោមៈ

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោកស្រី [redacted] ជាចៅក្រម
៣-លោក [redacted] ជាចៅក្រម
៤-លោក [redacted] ជាចៅក្រម
៥-លោក [redacted] ជាចៅក្រម

ក្រឡាបញ្ជី
លោក [redacted]

តំណាងមហាអយ្យការ
លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ០៣ "ឋ" ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៨២ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ របស់តុលាការកំពូល។

តបទៈ ឆបោក ប្រព្រឹត្តនៅភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី២០០៥។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២។

-ជនជាប់ចោទឈ្មោះ [redacted] ចន្ទាវុធ ម្ចាស់បណ្តឹងសាទុក្ខ ភេទស្រី អាយុ២៥ឆ្នាំ ជាតិខ្មែរ របរកពេទ្យឈ្នួល កើតនៅភូមិពោធិបាក់ក ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ ទីលំនៅភូមិកំពង់រទេះ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ។ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្តីឈ្មោះ [redacted] មានកូន០២នាក់ ទោសពីមុនគ្មាន ឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ធំ ។

មានលោក[redacted]វិបុល ជាមេធាវីការពារ

69

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចារ៉ី ចុងបណ្តឹងសាមុគ្គ (តំណាង) ភេទស្រី អាយុ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិកមណ្ឌលសុខភាពខេត្តកំពង់ធំ មានទីលំនៅ[illegible] ភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។

កាលពីអំឡុងឆ្នាំ២០០០ ជនជាប់ចោទឈ្មោះ [redacted] ចន្ទាវុធ បានធ្វើជាមេតុងទីន ដោយមានសមាជិកតុងទីនជាង១៨នាក់ គឺក្នុងនោះមានក្បាល ៥០.០០០រៀល និងក្បាល ១០០.០០០រៀល ហើយសមាជិកតុងទីនដែលឈ្មោះ [redacted] ចន្ទាវុធ ជំពាក់ប្រាក់នោះ គឺមានឈ្មោះ និងចំនួនប្រាក់ដូចខាងក្រោមៈ

| | |
|---|---|
| ១. ឈ្មោះ [redacted] ស៊ីនថាន | ចំនួន ២.៥០០.០០០រៀល |
| ២. ឈ្មោះ [redacted] ផែលាក | ចំនួន ២.៥០០.០០០រៀល |
| ៣. ឈ្មោះ [redacted] ស្រីប៊ុម | ចំនួន ៧.៨៥០.០០០រៀល |
| ៤. ឈ្មោះ [redacted] ហ៊ន់វៀន | ចំនួន ១.៧០០.០០០រៀល |
| ៥. ឈ្មោះ [redacted] សោភា | ចំនួន ១.៣០០.០០០រៀល |
| ៦. ឈ្មោះ [redacted] សាគី | ចំនួន ១.៦០០ ០០០រៀល |
| ៧. ឈ្មោះ [redacted] សៀងឡេង | ចំនួន ២ ០០០ ០០០រៀល |
| ៨. ឈ្មោះ [redacted] | ចំនួន ១ ០០០.០០០រៀល |
| ៩. ឈ្មោះ [redacted] សុខជា | ចំនួន ២.៣០០.០០០រៀល |
| ១០. ឈ្មោះ [redacted] សាគ័ណ្ហ | ចំនួន ៣ ០០០.០០០រៀល |
| ១១. ឈ្មោះ [redacted] សុខុន | ចំនួន ១ ៩៥០.០០០រៀល |
| ១២. ឈ្មោះ [redacted] ណៃអៀង | ចំនួន ១ ៩៥០.០០០រៀល |
| ១៣. ឈ្មោះ [redacted] សាក់រ៉េត | ចំនួន ៦.១០០ ០០០រៀល |
| ១៤. ឈ្មោះ [redacted] ស៊ីឈៀន | ចំនួន ៧.០០០ ០០០រៀល |
| ១៥. ឈ្មោះ [redacted] ប៊ីយ៉ុក | ចំនួន ៦.៥៤០ ៨០០រៀល |
| ១៦. ឈ្មោះ [redacted] ក៉លិន | ចំនួន ១ ០០០.០០០រៀល |
| ១៧. ឈ្មោះ [redacted] សុផន | ចំនួន ៣ ០០០ ០០០រៀល |
| ១៨. ឈ្មោះ [redacted] ចារ៉ី | ចំនួន ៧ ១០០ ០០០រៀល |

នៅពេលប្រមូលប្រាក់តុងទីនបានហើយ ជនជាប់ចោទឈ្មោះ [redacted] ចន្ទាវុធ បានប្រើល្បិចកលភូតភរ ដល់សមាជិកតុងទីនថា សមាជិកនេះឬសមាជិកនោះដេញបានបន្តបន្ទាប់ជារៀងរាល់ខែ ហើយលុះដល់ថ្ងៃខែមិនា ឆ្នាំ២០០៤ ជនជាប់ចោទក៏គេចខ្លួនបាត់ដោយពុំបានធ្វើការទូទាត់ប្រាក់ឲ្យសមាជិកតុងទីនដែលនៅសល់ឡើយ។

Scanned by CamScanner

64/5

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ធំជា ចោទប្រកាន់លើឈ្មោះ [redacted] ចន្ទាវុធ ភេទស្រី អាយុ៤៣ឆ្នាំ ជាតិខ្មែរ របររកស៊ីពេទ្យឈ្មួល ទីលំនៅបច្ចុប្បន្នភូមិកំពង់ធំ ឃុំកំពង់រទេះ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ទោសពីមុន -គ្មាន- ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្តីឈ្មោះ ហួត ហួន មានកូន០២នាក់ ពីបទៈ ឆបោក តាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅមន្ទីរពេទ្យ ខេត្តកំពង់ធំ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ២៧ -គ- ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកំពង់ធំ ដែលបានសំរេចៈ

១-ផ្តន្ទាទោសឈ្មោះ [redacted] ចន្ទាវុធ អាយុ៤៥ឆ្នាំ ភេទប្រុស ជាតិខ្មែរ កំណត់ពន្ធនាគាររយៈពេល២ឆ្នាំ ពីបទៈ ឆបោក ប្រព្រឹត្តនៅភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីឆ្នាំ២០០៥ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២។

២-បង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] ចន្ទាវុធ ក្នុងពេលនេះតែម្តង។

៣-បង្គាប់ឲ្យសងសំណង និងជំងឺចិត្តចំនួន៦០.៤០០.០០០រៀល និងជម្ងឺចិត្តសរុបជាប្រាក់ចំនួន១៦.៩០០.០០០រៀល ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីដែលមានឈ្មោះ [redacted] ជាវ៉ូ សំណូមពរលើសពីនេះត្រូវបដិសេធចោល ដែលក្នុងនោះត្រូវសងទៅៈ

-ឈ្មោះ [redacted] ស៊ុនថាន ចំនួន២.៥០០.០០០៛ និងជម្ងឺចិត្តចំនួន ៥០០.០០០៛។
-ឈ្មោះ [redacted] ចែលោក ចំនួន ២.៥០០.០០០៛ និងជម្ងឺចិត្តចំនួន ១.០០០.០០០៛។
-ឈ្មោះ [redacted] ស្រីប៉ុម ចំនួន ៧.៨៥០.០០០៛ និងជម្ងឺចិត្តចំនួន ៣.០០០.០០០៛។
-ឈ្មោះ [redacted] វ៉ាន់រឿន ចំនួន ១.៧០០.០០០៛ និងជម្ងឺចិត្តចំនួន ១០០.០០០៛។
-ឈ្មោះ [redacted] សោភា ចំនួន ១.៣០០.០០០៛ និងជម្ងឺចិត្តចំនួន ៥០.០០០៛។
-ឈ្មោះ [redacted] សាគី ចំនួន ១.៦០០.០០០៛ និងជម្ងឺចិត្តចំនួន ១០០.០០០៛។
-ឈ្មោះ [redacted] សៀងឡេង ចំនួន ២.០០០.០០០៛ និងជម្ងឺចិត្តចំនួន ១០០.០០០៛។
-ឈ្មោះ [redacted] វ៉ា ចំនួន ១.០០០.០០០៛ និងជម្ងឺចិត្តចំនួន ១០០.០០០៛។
-ឈ្មោះ [redacted] សុខជា ចំនួន ២.៣០០.០០០៛ និងជម្ងឺចិត្តចំនួន ១០០.០០០៛។
-ឈ្មោះ [redacted] សោភ័ណ្ឌ ចំនួន ៣.០០០.០០០៛ និងជម្ងឺចិត្តចំនួន ១.០០០.០០០៛។
-ឈ្មោះ [redacted] សុខខុន ចំនួន ១.៩៥០.០០០៛ និងជម្ងឺចិត្តចំនួន ១.០០០.០០០៛។
-ឈ្មោះ [redacted] ណៃអៀង ចំនួន១.៩៥០.០០០៛ និងជម្ងឺចិត្តចំនួន ១.០០០.០០០៛។
-ឈ្មោះ [redacted] សាក់វែត ចំនួន៦.១០០.០០០៛ និងជម្ងឺចិត្តចំនួន ៣.០០០.០០០៛។



Scanned by CamScanner

69/4

-ឈ្មោះ[redacted]ស៊ុយឿន ចំនួន ៧.០០០.០០០៛ និងជម្ងឺចិត្តចំនួន ២.០០០.០០០៛។

-ឈ្មោះ [redacted] ប៊ីយ៉ុក ចំនួន ៦.៥៥០.០០០៛ និងជម្ងឺចិត្តចំនួន ៣.០០០.០០០៛។

-ឈ្មោះ[redacted] ម៉ាលើន ចំនួន ១.០០០.០០០៛ និងជម្ងឺចិត្តចំនួន ១០០.០០០៛។

-ឈ្មោះ [redacted]សុថន ចំនួន ៣.០០០.០០០៛ និងជម្ងឺចិត្តចំនួន ១០០.០០០៛។

-ឈ្មោះ[redacted]ជារ៉ូ ចំនួន ៧.១០០.០០០៛ និងជម្ងឺចិត្តចំនួន ២០០.០០០៛។

៤-សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈកំបាំងមុខតុលាការ បើកសិទ្ធឲ្យប្តឹងទាស់ក្នុងរយៈពេល១៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលដំណឹងពីសាលក្រមកំបាំងមុខ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេល១ខែ គិតចាប់ពីថ្ងៃផុតបណ្តឹងទាស់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ១៦ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] ចន្ទាវុធ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខសាលក្រមព្រហ្មទណ្ឌលេខ២៧ "ត" ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកំពង់ធំ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថាៈ សំរេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ២៧ "ត" ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកំពង់ធំ ទុកជាបានការដដែល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០៣ "ប" ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចៈ

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ១៦ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០ របស់ពិរុទ្ធជនឈ្មោះ ស៊ុន ចន្ទាវុធ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់។

២-តំកល់សាលក្រមព្រហ្មទណ្ឌលេខ២៧ "ត" ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកំពង់ធំ ទុកជាបានការលើកលែងតែចំណុចទី១ ត្រូវកែប្រែដូចខាងក្រោម៖

-ចំណុចទី១ នៃសាលក្រមត្រង់ (ដាក់ពន្ធនាគារចំនួន២ឆ្នាំ) ត្រូវកែប្រែជាដាក់ពន្ធនាគារចំនួន២ឆ្នាំ តែទោសនេះត្រូវអនុវត្ត ៖

-ទោសដាក់ពន្ធនាគារ២ខែ ១៥ថ្ងៃ គិតពីថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១០។

-ទោសនៅសល់ត្រូវព្យួរ (ទោសព្យួរធម្មតា)។ ចំណុចក្រៅពីនោះនៅរក្សាទុកដដែលតាមមាត្រា ១០៧, ១០៨ នៃក្រមព្រហ្មទណ្ឌ។

៣-សាលដីកានេះជំនុំជម្រះ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០ ចំពោះមុខតំណាងដើមបណ្តឹងឈ្មោះ[redacted]ារ៉ូ កំបាំងមុខពិរុទ្ធជនឈ្មោះ [redacted] ចន្ទាវុធ។

បើកសិទ្ធិឲ្យប្ដឹងទាស់ និងប្ដឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញបណ្ដឹងសាទុក្ខលេខ១៣៧ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] ចន្ថាវុធ ប្ដឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ០៣ "ប" ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

-បានឃើញសារណាការពាររបស់ឈ្មោះ [redacted] ចន្ថាវុធ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១។

-បានឃើញសារណាតបរបស់ឈ្មោះ [redacted] ញ៉ូ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១១។

-បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការតុលាការកំពូលថា: ដើម្បីការពារផលប្រយោជន៍ច្បាប់ និងផលប្រយោជន៍យុត្តិធម៌ចំពោះជនរងគ្រោះចំពោះសំណុំរឿងនេះតំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋានស្នើសុំក្រុមប្រឹក្សាជំនុំជំរះសំរេចទទួលយកបណ្ដឹងសាទុក្ខដូចបញ្ជាក់ខាងលើដោយចាត់ទុកជាត្រូវខ្វះ និងខុសខ្វះ និងតម្កល់សាលដីការបស់សាលាឧទ្ធរណ៍លើកលែងតែចំណុចស្ដីពីសំណងជំងឺចិត្តដែលត្រូវបដិសេធចោល។

-បានស្ដាប់ក្រឡាបញ្ជីអានសារណាការពារ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ចន្ថាវុធ។

-បានស្ដាប់ក្រឡាបញ្ជីអានសារណាតប ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ញ៉ូ។

-បានស្ដាប់សេចក្ដីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា: គ្មានយោបល់អ្វីបន្ថែមទៀតទេ។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សារណារបស់គូក្ដី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

**តុលាការកំពូល**

-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ១៣៧ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] ចន្ថាវុធ ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា១៦ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន។

Scanned by CamScanner

-យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ចន្ទាវុធ ប្តឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ០៣-ឋ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍តែត្រង់បំណុចសំណង និងជម្ងឺចិត្តប៉ុណ្ណោះ។ ឯចំពោះទណ្ឌកម្មវិញ គឺត្រូវបានចូលជាស្ថាពររួចហើយ។

-យល់ឃើញថា តាមសារណាការពារ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ចន្ទាវុធ ថា ខ្លួនទទួលស្គាល់ការជំពាក់របស់កូនតុងទីន ឈ្មោះ១-[redacted] ស៊ីថាន, ២[redacted] លោក [redacted] ប៊ីយ៉ុកុំ [redacted] វ៉ាន់រឿន, ៥-[redacted] សោភា, [redacted] សាគី, [redacted] សៀងឡេង, [redacted] វ៉ា, ៩-[redacted] សុខជា, ១០-[redacted] សោភ័ណ្ឌ, ១១-[redacted] សុខុន, ១២[redacted] ណាអៀង, ១៣[redacted] សាវ៉ាវេត ១៤[redacted] ម៉ាលីន, ១៥-[redacted] សុថុន និង១៦[redacted] តារ៉ូ។ ដោយឡែកកូនតុងទីនឈ្មោះ [redacted] ប៊ុម គាត់ទាមទារប្រាក់ដើមពីនាងខ្ញុំ ៧.៨៥០.០០០រៀល តែនាងខ្ញុំជំពាក់គាត់តែ៤.៧០០.០០០រៀលទេ និងជំពាក់ប្រាក់ឈ្មោះ [redacted] សាំង៣.១៥០.០០០រៀល និងឈ្មោះ [redacted] ស៊ុឃៀន វិញ គាត់ទាមទារពីខ្លួន៧លានរៀល តែខ្លួនជំពាក់គាត់តែ៣.៣៥០.០០០រៀលទេ។ ឃើញថាការលើកឡើងនេះ មិនទាន់ត្រូវបានសាលាដំបូង និងសាលាឧទ្ធរណ៍ពិចារណានៅឡើយ។

-យល់ឃើញថា ចំពោះសំណងជម្ងឺចិត្តវិញ សាលាដំបូងខេត្តកំពង់ធំក៏ដូចជាសាលាឧទ្ធរណ៍ ដែលបានសម្រេចសមស្របទៅនឹងព្យសនកម្មនៃអំពើល្មើស ហើយលើកលែងតែការសំរេចអំពីសំណងជម្ងឺចិត្ត ហើយលើកលែងតែការសំរេចអំពីសំណងជម្ងឺចិត្តលើឈ្មោះ [redacted] វ៉ា ដែលលើសពីការទាមទារ ដែលគប្បីពិចារណាជាថ្មី។

-យល់ឃើញថា គូក្តីត្រូវបានអយ្យការអមតុលាការកំពូល កោះហៅចូលរួមសវនាការត្រឹមត្រូវតាមនីតិវិធី ក៏ប៉ុន្តែមិនចូលខ្លួន តែបានដាក់សារណាការពារ និងសារណាឆ្លើយតបរួចហើយ។ ដូចនេះគប្បីតុលាការកំពូលលើកយករឿងក្តីនេះមកជំនុំជំរះ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ០៣-ឋ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ខ្លះ ខុសខ្លះ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-បដិសេធផ្នែកខ្លះ និងទទួលផ្នែកខ្លះនៃបណ្តឹងសាទុក្ខលេខ១៣៧ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] ចន្ទាវុធ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ០៣-ឋ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ទុកជាបានការលើកលែងតែសំណង និងជម្ងឺចិត្តលើបណ្តឹងទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីប៊ុម, [redacted] ស៊ុឃៀន និងសំណងជម្ងឺចិត្តដែលប្តឹងទាមទារ ដោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វ៉ា ត្រូវបដិសេធចោល។

Scanned by CamScanner

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៨៤ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មី លើបណ្តឹងទាមទារសំណង និងជម្ងឺចិត្ត របស់ឈ្មោះ [redacted] ស្រីប៉ុម, សុខ ស៊ីឈៀន និងបណ្តឹងទាមទារសំណងជម្ងឺចិត្តរបស់ឈ្មោះ [redacted]។

៤-សាលដីកានេះជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

---

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។

រាជធានីភ្នំពេញ ថ្ងៃទី 03 ខែ មករា ឆ្នាំ២០១៣

ក្រឡាបញ្ជី

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី 03 ខែ មករា ឆ្នាំ២០១៣

ជ. ប្រធានតុលាការកំពូល

អនុប្រធាន